# អ្នកនឹងត្រូវគេចាប់បាន. បញ្ចប់ការយកកុមារជាទាសករសំរាប់តណ្ហា

www.youwillbecaught.com

## អ្នកនឹងត្រូវផ្តន្ទារទោស

ប្រទេសចំនួន២៣បានធ្វើឲ្យមានច្បាប់នៃការត្រួតត្រានៅក្រៅដំបន់ ដើម្បីកាត់ទោសជនដែលប្រើ ទាសករសំរាប់តណ្ហានៅបរទេស។

នៅអាស៊ីភាគអគ្នេយ៍,ជនយកកុរមារាកុមារីជាទាសករសំរាប់តណ្ហាត្រូវប្រឈមមុខទទួលនូវការផ្តន្ទារទោសនៃស្រុកដូចជាៈ ការពិន័យជាប្រាក់យ៉ាងច្រើន, ការដាក់ពន្ធាគារយ៉ាងធ្ងន់ និងការធ្វើឲ្យអាម៉ាសមុខនៅទីសាធារណៈ។

ចាងហ្វាងសាលារៀនម្នាក់នៃប្រទេសអគ្លេស ចន ឃាលឡឺរ បានត្រូវជាប់ទោសនិងដាក់ឃុំនៅក្នុងពន្ធាគារនៃប្រទេសកម្ពុជាពីបទចាប់កុមារមក រួមភេទ - បើទោះជាគេបានប៉ុនប៉ងសូកប៉ាន់អ្នកផ្លូវការយ៉ាងណាក៏ដោយ។

"ខ្ញុំនឹងបង់ប្រាក់ ប៦$៥,៤០០។ ខ្ញុំជឿថានឹងបានរួចខ្លួន។ ខ្ញុំនឹងស្លាប់បើគេដាក់ខ្ញុំឲ្យនៅក្នុងរណ្តៅនោះវិញ" ប្រិទីសណាស្ទួនណាល ចន ឃាឡឺរ

## គ្រោះដែលអាចមានដល់សុខភាពដែលអ្នកគួរតែដឹង

ជាងពាក់កណ្តាលនៃចំនួនជនទាសករសំរាប់តណ្ហានៅអាស៊ីភាគអាគ្នេយ៍ត្រូវឆ្លងរោគអេចអាយវី ឬអេដស៍

រាប់សិបពាន់នៃជនដែលចាប់កុមារមករួមភេទ បាននាំមកស្រុកវិញនូវជម្ងឺរប្រចាំជីវិតដូចជា អេចអាយវី ឬអេដស៍, រោគប្រមេះ, រោគស្វាយ, អង្គជាតិកើតឬស្ស, រោគរមាស់ជាដើម និងរោគ ផ្សេងៗជាច្រើនទៀតដែល ឆ្លងដោយការរួមភេទ។

សាកគិតមើលពីលទ្ធផលនៃ " អនុស្សាវរីយ៍ដែលមិនបានស្មានទុកជាមុន " នេះ ដែលអ្នកនាំទៅផ្ទះអ្នកវិញពី "វិស្សមកាលនៃស្នេហា " តើនឹងមានផលយ៉ាងណាទៅលើគ្រួសារអ្នក, កូនអ្នកនឹងកន្លែងអ្នកធ្វើការ

ជនជាតិជប៉ុនម្នាក់បានទិញ "ក្រមុំព្រហ្មចារីយ" ចំនួន៣០នាក់ រវាងអាយុពី ៨ ទៅ ១៧ឆ្នាំ។ គាត់ចង់ប៉ូវខ្លួនចាស់របស់គាត់ឲ្យក្មេងឡើងវិញ។ គាត់បានទទួលជម្ងឺអេដស៍ទៅវិញ។

## រាយការណ៍ពីជនពិរុទ្ធក(អ្នកប្រព្រឹត្តបទមជ្ឈឹម)

អ្នកអាចរាយការណ៍ពីជនជាប់ការសង្ស័យពីពិរុទ្ធករ ទៅអាជ្ញាធរក្នុងស្រុកអ្នក។ គេនឹងទៅជាកម្មវត្ថុទៅតាមច្បាប់នៃស្រុកទេសទោះបីជាគេមកពីណាស្រុកណាក៏ដោយ។ នៅប្រទេសកម្ពុជាសូមទូរស័ព្ទទៅលេខ +៨៥៥ (0) ២៣ ៧២០ ៥៥៥(ទូរស័ព្ទសំរាប់ពេលប្រថុចញ្ចៀចនៃក្រសួងមហាផ្ទៃកម្ពុជា)ដើម្បីរាយការណ៍ពីជនជាប់ការសង្ស័យពីពិរុទ្ធករ។

បើអ្នកស្គាល់ពីសញ្ញាតិនៃ ពីជនជាប់ការសង្ស័យពីពិរុទ្ធករ, សូមរាយការណ៍ទៅស្ថានទូតរបស់គេ ហើយគេនឹងត្រូវទទួលការកាត់ទោសនៅប្រទេសរបស់គេ។

ជនជាតិអូស្ត្រាលីម្នាក់មានអាយុ៤៥ឆ្នាំ បានកាត់ទោសជាប់គុក ១២ឆ្នាំ ពីបទរួមភេទទៅលើកុមារខ្មែរចំនួន ២៤ករណីយ។ ជននោះមិនមែនចាប់បានដោយក្រសួងគយនិងអន្តោប្រវេសន្តឡើយ ប៉ុន្តែគឺដោយសារការរាយការណ៍ពីអ្នករួមការងារម្នាក់ដែលខ្ពើមរអើមចំពោះអំពើនៃជននោះនៅពេលដែលបានឃើញរូបថតដែលជននោះបានបង្ហាញទៅគាត់។ ការរាយការណ៍ពីជនជាប់ការសង្ស័យពីពិរុទ្ធករ អាចជួយជីវិតនឹងជាការបង្ហាញឲ្យឃើញជាក់ច្បាស់ថា គឺជាអំពើដ៏ត្រឹមត្រូវដែលត្រូវធ្វើ។

---

អ្នកអាចរាយការណ៍ពីជនជាប់ការសង្ស័យពីពិរុទ្ធករពីកន្លែងណាក៏បានដែរនៅក្នុងពិភពលោកយើងនេះនៅឯ www.youwillbecaught.com
ភ្នាក់ងារនៃច្បាប់ដាក់ឲ្យប្រត្តិបត្តិនៅក្នុងតំបន់ និងតាមអន្តរៈជាតិ ដែលត្រូវការជំនួយពីអ្នក ដើម្បីជួយការពារដល់កុមារាកុមារីទាំងនេះ។ ការឲ្យដំណឹងទាំងនេះនឹងធ្វើទៅដោយមានការលាក់ជាការសម្ងាត់យ៉ាងប្រយ័ត្នប្រយែងជាទីបំផុត។

ការទទួលខុសត្រូវចំពោះផ្នែកទេសចរ, គំរោងការរបស់ក្រុមអនាគត (The Future Group) http://www.thefuturegroup.org

---